ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

លេខ ៦១២...០២២...៧៤៣...ប្រកាសព័ត៌មាន

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០២២

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## សិក្ខាសាលាផ្សព្វផ្សាយសេចក្តីណែនាំពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលចេញដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

នៅថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២២ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សហការជាមួយសមាគមធនាគារនៅកម្ពុជា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយសេចក្តីណែនាំចំនួន ៣ រួមមាន ៖

១/- សេចក្តីណែនាំស្តីពីការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍

២/- សេចក្តីណែនាំស្តីពីការផ្ទេរប្រាក់ និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក និង

៣/- សេចក្តីណែនាំស្តីពីទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែល។

សិក្ខាសាលាផ្សព្វផ្សាយនេះ មានបំណងលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ ដែលជាគ្រឹះស្ថានធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង សេចក្តីណែនាំពាក់ព័ន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ សិក្ខាសាលានេះមានសិក្ខាកាមចូលរួម ចំនួនប្រមាណ ៨៥រូប មកពីគ្រឹះស្ថានចំនួន ៦៨។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.org.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA